# ប្រយោជន៍នៃក្រុមចង្កោមចំពោះកិច្ចគាំទ្រគ្រួសារធម៌

Better Care Network

## សេចក្តីសង្ខេបអំពីវីដេអូ

ធាតុផ្សំមួយដ៏សំខាន់ដើម្បីគាំទ្រកុមារនៅក្នុងគ្រួសារធម៌ប្រកបដោយប្រសិទ្ធភាព គឺជាការផ្ដល់នូវកិច្ចគាំទ្រផ្នែកសង្គមឱ្យបានគ្រប់គ្រាន់ដល់អ្នកថែទាំ។ ក្នុងករណីដែលកិច្ចគាំទ្រនេះពុំមានផ្ដល់ជូន ឬ ផ្ដល់ជូនមិនទាន់ពេលវេលា នាំឱ្យបញ្ហាដែលគ្រួសារធម៌ជួបប្រទះអាចកើនឡើង និង នាំឱ្យប៉ះពាល់ដល់គុណភាពនៃការថែទាំកុមារ និង/ឬ នាំឱ្យការទុកដាក់កុមារគ្មានស្ថេរភាព និង បែកបាក់។ ការផ្ដល់កិច្ចគាំទ្រផ្នែកសង្គមឱ្យបានគ្រប់គ្រាន់ ក្រោមមូលដ្ឋានមួយទល់នឹងមួយ អាចត្រូវចំណាយច្រើន និង អាចនាំឱ្យមានតម្រូវការខ្ពស់ចំពោះបុគ្គលិកសង្គមកិច្ច។ ករណីនេះកាន់តែមានភាពធ្ងន់ធ្ងរឡើង ក្នុងស្ថានភាពដែលបុគ្គលិកសង្គមកិច្ចត្រូវធ្វើដំណើរផ្លូវឆ្ងាយ ដើម្បីជួបជាមួយគ្រួសារធម៌។

នៅក្នុងវីដេអូនេះ អ្នកនឹងស្ដាប់លឺពី កែវ រ៉ាវី និង ឈួន លក្ខណ៍ ដែលជាបុគ្គលិកសង្គមកិច្ចរបស់អង្គការកុមារក្នុងគ្រួសារ ខណៈពេលដែលពួកគេចែករំលែកបទពិសោធណ៍របស់ពួកគេដោយប្រើប្រាស់គំរូលក្ខណៈជាក្រុមចង្កោម ដើម្បីលើកកម្ពស់កិច្ចគាំទ្រផ្នែកសង្គមដែលមានសម្រាប់ឪពុកម្ដាយធម៌ ហើយស្របពេលជាមួយគ្នានេះ ក៏កាត់បន្ថយតម្រូវការដែលផ្ដោតទៅលើធនធានរបស់អង្គការផងដែរ។ រ៉ាវី និង លក្ខណ៍ នឹងពិភាក្សា អំពីចំណុចរៀនសូត្រសំខាន់ៗរបស់ពួកគេ ពាក់ព័ន្ធនឹងផលប៉ះពាល់របស់ក្រុមចង្កោម អ្នកថែទាំដោយឪពុក ម្ដាយធម៌ ទៅលើការកាត់បន្ថយវិបត្តិតានតឹងរបស់អ្នកថែទាំ ដោយលើកកម្ពស់ជំនាញដោះស្រាយបញ្ហា ស្ថេរភាពនៃការទុកដាក់កុមារ និង ការកសាងសមត្ថភាពរបស់អ្នកថែទាំតាម រយៈការលើកកម្ពស់ការរៀនសង្កេតពីក្រុមគ្រួសារថែទាំដទៃ។ ពួកគេនឹងបន្តចែករំលែកចំណេះដឹងរបស់ពួកគេបន្ថែមទៀត អំពីការសម្របសម្រួលប្រកបដោយ ប្រសិទ្ធភាពនៃកិច្ចប្រជុំក្រុមចង្កោម និង វិស័យសមត្ថភាពសំខាន់ៗដែលបុគ្គលិកសង្គមកិច្ចត្រូវមាន។

## សំនួរពិភាក្សាសម្រាប់អ្នកអនុវត្តការងារ

### ចំណុចពិភាក្សា៖

### កិច្ចគាំទ្រផ្នែកសង្គមមិនផ្លូវការ

នៅក្នុងវីដេអូនេះ រ៉ាវី និងលក្ខណ៍ ពិភាក្សាអំពីទំនាក់ទំនងរវាងអារម្មណ៍របស់អ្នកថែទាំកុមារ ដែលមានអារម្មណ៍ឯកោ និង វិបត្តិតានតឹងរ៉ាំរ៉ៃ។ ពួកគេរៀបរាប់ឱ្យដឹងអំពីសារៈសំខាន់នៃការបង្កើតបណ្ដាញគាំទ្រសង្គមបែបមិនផ្លូវការ ដែលរួមមានមិត្តភក្តិដែលមានបទពិសោធន៍ស្រដៀងគ្នា ដើម្បីកាត់បន្ថយវិបត្តិតានតឹងរ៉ាំរ៉ៃនៅក្នុងគ្រួសារធម៌ និង របៀបដែលក្រុមចង្កោមបានបង្កលក្ខណៈឱ្យសកម្មភាពនេះអាចប្រព្រឹត្តទៅបាន។

### នៅក្នុងបរិបទរបស់អ្នក៖

- តើអ្វីទៅជាសារៈសំខាន់នៃកិច្ចគាំទ្រសង្គមបែបមិនផ្លូវការសម្រាប់គ្រួសារ និងកុមារដែលអ្នកកំពុងធ្វើការងារជាមួយ? តើបណ្ដាញគាំទ្រសង្គមបែបមិនផ្លូវការនេះ អាចដោះស្រាយ ឬ កាត់បន្ថយបញ្ហា និងប្រភពវិបត្តិតានតឹងអ្វីខ្លះ? តើសកម្មភាពនេះនឹងនាំឱ្យផ្ដល់ជាប្រយោជន៍អ្វីខ្លះសម្រាប់កុមារ គ្រួសារ សហគមន៍ និងកម្មវិធីរបស់អ្នក?
- តើអ្នកអាចលើកកម្ពស់បណ្ដាញគាំទ្រសង្គមបែបមិនផ្លូវការតាមរយៈកម្មវិធី និងសកម្មភាពរបស់អ្នក ដោយរបៀបណា?
- តើអ្វីខ្លះជាយន្តការ និងសញ្ញាណធនធាន សម្រាប់អង្គការរបស់អ្នកធ្វើការងារនេះ?

### ចំណុចពិភាក្សា៖

## ការរៀនសង្កេតពីក្រុមគ្រួសារថែទាំដទៃ

នៅក្នុងវីដេអូនេះ អ្នកអនុវត្តការងារទាំងពីរនាក់ ពិភាក្សាអំពីការបង្កើនភាពសក្តិសិទ្ធនៃការរៀនសង្កេត ឬ ការធ្វើជាគំរូ ទាក់ទងនឹងការរក្សាព័ត៌មាន និងការកសាងសមត្ថភាពរបស់អ្នកថែទាំ និងមិនមែនជាការបង្រៀន ឬ ការបណ្តុះបណ្តាលដែលមានមូលដ្ឋានផ្អែកលើមេរៀនឡើយ។ វប្បធម៌មានឥទ្ធិពលយ៉ាងធំធេងទៅលើបែបផែននៃការរៀនសូត្ររបស់បុគ្គល និងសហគមន៍ ហើយវាក៏ជាកត្តាកំណត់ថាតើការរៀនសង្កេត ឬ ការរៀនសូត្របែបអរូបី នឹងមានកម្រិតភាគរយខ្ពស់ជាង ឬយ៉ាងណា។

## នៅក្នុងបរិបទរបស់អ្នក៖

- តើអ្វីទៅជាបែបផែននៃការរៀនសូត្រចម្បងរបស់បុគ្គល គ្រួសារ ឬ សហគមន៍ដែលអ្នកកំពុងធ្វើការងារជាមួយ? តើអ្នកមានភស្តុតាងតាមរយៈប្រភពមិនផ្លូវការ ឬ ភស្តុតាងជាក់ស្តែងអ្វីខ្លះសម្រាប់គាំទ្រអំណះអំណាងនេះ?
- តើបច្ចុប្បន្ន អ្នកផ្តល់ការបណ្តុះបណ្តាល ឬ សម្របសម្រួលការងារកសាងសមត្ថភាពយ៉ាងដូចម្តេច និងតើការងារនេះឆ្លុះបញ្ចាំងអំពីបែបផែននៃការរៀនសូត្រដូចម្តេចខ្លះ? តើវាមានសង្គតភាពទៅនឹង បែបផែននៃការរៀនសូត្រចម្បងដែលអ្នកបានកំណត់រកឃើញ ដែរឬទេ?
- តើអ្នកនឹងកែលម្អភាពសក្តិសិទ្ធ និង សម្របសម្រួលឱ្យមានឱកាសកាន់តែច្រើន សម្រាប់ការរៀនសង្កេតពីក្រុមគ្រួសារថែទាំដទៃ។ ឬ ការរៀនសូត្រពីអ្នកដទៃដោយប្រយោលដោយរបៀបណា ក្នុងករណីមានភាពពាក់ព័ន្ធ?

### ករណីសិក្សា

ដារ៉ា បានមកទទួលការថែទាំនៅឯ CIF នៅអាយុ៣ឆ្នាំ។ គាត់គឺជាកុមារម្នាក់ដ៏គួរឱ្យស្រឡាញ់ ដែលបត់បែនជីវិតរស់នៅរបស់គាត់យ៉ាងងាយស្រួលជាមួយឪពុកម្តាយធម៌ថ្មីរបស់គាត់។ ឪពុកម្តាយធម៌របស់គាត់មានការរំភើបក្នុងការធ្វើជាឪពុកម្តាយ និង បានស្វាគមន៍គាត់ដែលបានចូលមកក្នុងជីវិតរបស់ពួកគេ សហគមន៍របស់ពួកគេ និងទម្លាប់គ្រួសាររបស់ពួកគេ។ ក្នុងរយៈពេល៥ឆ្នាំបន្ទាប់ ដារ៉ា និងគ្រួសារធម៌របស់គាត់ត្រូវបាន បុគ្គលិកសង្គមកិច្ចរបស់ CIF មកសួរសុខទុក្ខជាទៀងទាត់ ដោយបានជួយដល់ពួកគេក្នុងការកំណត់គោលដៅក្នុងលក្ខណៈជាគ្រួសារ ព្រមទាំងអបអរសាទរជាមួយគ្រួសារ ខណៈពេលដែលដារ៉ាចម្រើនវ័យឡើងមានភាពរឹងមាំមានសុខភាពល្អ និងចូលរៀន។

នៅពេលដែលដារ៉ាឈានដល់អាយុ៨ឆ្នាំ បុគ្គលិកសង្គមកិច្ចមានភាពភ្ញាក់ផ្អើលនៅពេលដែលស្ថានភាពនៃកិច្ចសន្ទនានៅឯកិច្ចប្រជុំប្រចាំខែរបស់ពួកគេមានការប្រែប្រួល។ ឪពុកម្តាយមានការលំបាកខ្លាំងក្នុងការគ្រប់គ្រងទៅលើការប្រព្រឹត្តរបស់ដារ៉ា។ ដារ៉ារក់លេងខ្លាំងពេក និង ធ្វើតែអ្វីដែលគាត់ចង់ធ្វើហើយមិនស្តាប់បង្គាប់ឪពុកម្តាយ ឬ ជួយការងារក្នុងគ្រួសារដោយឆន្ទៈពីក្នុងចិត្ត ដូចមុនឡើយ។ ឪពុកម្តាយបានសម្រេចចិត្តថាពួកគេចង់ឱ្យ CIF យកដារ៉ាទៅវិញ អាស្រ័យដោយពួកគេមិនអាចចិញ្ចឹមបីបាច់ដារ៉ាបាន។ ក្នុងអំឡុងពេលនៃកិច្ចពិភាក្សានេះ បុគ្គលិកសង្គមកិច្ចបានផ្តល់មតិយោបល់មួយចំនួនទៅឱ្យគ្រួសារ អំពីរបៀបប្រព្រឹត្តចំពោះកុមារ និងជួយលើកទឹកចិត្តឱ្យមានការប្រព្រឹត្តវិជ្ជមាន។ គ្រួសារនេះនៅតែមានមន្ទិលសង្ស័យអំពីមតិយោបល់ទាំងនេះ។ នៅឯកិច្ចប្រជុំតាមដានបន្តមួយ ឪពុកម្តាយនៅតែលើកឡើងនូវបញ្ហាកង្វល់ទាក់ទងនឹងការប្រព្រឹត្តរបស់កុមារ ហើយពួកគេមិនបានសាកល្បងបច្ចេកទេសដែលបុគ្គលិកសង្គមកិច្ចបានណែនាំឡើយ។

នៅដំណាច់ខែ គ្រួសារនេះបានចូលរួមនៅក្នុងកិច្ចប្រជុំក្រុមចង្កោមប្រចាំខែរបស់ពួកគេ។ ឪពុកម្តាយបានធ្វើការចែករំលែកដោយបើកចំហរ អំពីភាពតានតឹងរបស់ពួកគេចំពោះអាកប្បកិរិយារបស់ដារ៉ា។ អ្វីដែលធ្វើឱ្យពួកគេភ្ញាក់ផ្អើលគឺ មានម្តាយម្នាក់ទៀតដែលមានកូនធម៌អាយុប្រហាក់ប្រហែលគ្នា ក៏បានបង្ហាញនូវភាពតានតឹងរបស់គាត់ចំពោះអាកប្បកិរិយារបស់កូនគាត់ដែរ។ គាត់ហាក់បីដូចជាមានអារម្មណ៍អៀនខ្មាសបន្តិច ក្នុងការប្រាប់រឿងនេះឱ្យក្រុមបានដឹង អាស្រ័យដោយកន្លងមក គាត់គ្រាន់តែបានចែករំលែកអំពីរឿងនេះឱ្យ ប្តីរបស់គាត់បានដឹងប៉ុណ្ណោះ។ មានអ្នកម្តាយម្នាក់ដែលមានវ័យចំណាស់ជាងនេះ ដែលបានចិញ្ចឹមកូនបង្កើតរបស់គាត់ និងឥឡូវនេះគាត់កំពុងចិញ្ចឹមកូនតូចម្នាក់ ក៏បានងក់ក្បាលក្នុងលក្ខណៈយល់អំពីសាច់រឿង។ គាត់បានចែករំលែកបទពិសោធន៍របស់គាត់ អំពីអាកប្បកិរិយាស្រដៀងគ្នានៅពេលដែលកូនរបស់គាត់នៅតូច។ ការធ្វើបែបនេះបានជួយដល់គ្រួសារឱ្យមើលឃើញថាបញ្ហាមានទំនាក់ទំនងទៅនឹងវ័យរបស់កុមារ និងដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ និងមិនមែនដោយសារកូននោះជាកូនធម៌ឡើយ។ គ្រួសារទាំងបីនេះ មានអារម្មណ៍ថាបានទទួលការគាំទ្រ និងការលើកទឹកចិត្ត ក្រោយពេលមានឱកាសចែករំលែកអំពីបទពិសោធន៍របស់ពួកគេ និងពិភាក្សាអំពីយុទ្ធ សាស្ត្រសម្រាប់គ្រប់គ្រងអាកប្បកិរិយាកូនរបស់ពួកគេ។ កិច្ចគាំទ្រនេះ បានផ្តល់ឱ្យឪពុកម្តាយធម៌របស់ដារ៉ា នូវទំនុកចិត្ត និងការជឿជាក់ដែលពួកគេត្រូវការ ដើម្បីបន្តផ្តល់ការថែទាំជូនដារ៉ា។